D119523 DC-Cam

មជ្ឈមណ្ឌលឯកសារ

DOCUMENTATION CENTER

# Mapping Report:

# *Kampong Cham*

*CAMBODIA Office:* Post Office Box 1110
Phnom Penh, Tel: [855] 23-26152, Fax: [855] 23-26009

*US Office:* Post Office Box 208206
New Haven, Connecticut 06520, Tel: [203] 432-9346/7

# CGP SITE FORM

ID No. 030704 B -5 (P)

Site Name Wat Nikraoth Khmer..................

Date 20/2/96

Province K Cham District Kong Meas

Sub-District Peam Chi Kong Village Dom Nak Chrey Khmer..................

| Prison 030705 | Burial Site 030704 | Memorial |
|---|---|---|
| __Interrog Ctr. | ✓ Pit | __Wat |
| __Previous Prison | __Kiln | __Stupa |
| __Purpose Built | __Rice paddy | __Brick/tile |
| __School | __River/lake | __Wooden |
| ✓ Wat | __Well | __Other |
| __House | __Execution | |
| __Other | __Other | |

**Access:**

Route No......... .........Km from ..........................Condition ....................

Route No......... .........Km from ..........................Condition....................

**Estimated No of Victims** 11,160 **Mass graves** 186

**Contact Persons (Official)** ..........................................................

**Visited:** (Yes) / No **Team :** CB/HS

**Photos:** Roll # 1 Shots # 36-38

**Documents:** Name written in blood on column. Other names painted over by monks

Kum Kg No 3

**Interviews:**..........................................................

**Comments:** Wat used as prison. Mass graves in trees nearby. New people were asked to come + bring food, + were killed. Writing in blood on walls of Wat. Region Prison for Region 41. Killing from 1975 then moved to O Trau Kuan.

**Latitude:** N 11° 58' 14" **Longitude:** E 105° 16' 10"

**File No:** RO22 008 A **Time:** 1530

# CGP SITE FORM

Site Name: Wat Vihear Tuntum Khmer: វត្តវិហារទំទំ ID No. 031603 Date 21/2/96

Province: K-Cham District: Tbong Khmum
Sub-District: Suong Village: Suong Kaet Khmer

**Prison**
- __Interrog Ctr.
- __Previous Prison
- __Purpose Built
- __School
- __Wat
- __House
- __Other

**Burial Site**
- __Pit
- __Kiln
- __Rice paddy
- __River/lake
- __Well
- __Execution
- __Other

**Memorial** (circled)
- __Wat
- __Stupa
- __Brick/tile
- ✓ Wooden
- __Other

**Access:**

Route No. ...... 1 Km from Suong Condition ......

Route No. ...... Km from ...... Condition ......

**Estimated No of Victims** 100 + Skulls **Mass graves** ......

**Contact Persons (Official)** ......

**Visited:** Yes (circled) / No **Team:** CB/HS

**Photos:** Roll # 2 Shots # 3, 4, 5

**Documents:** ......

**Interviews:** Wa Phar – witness Sou Phem's body brought back to Suong on tank 1978

**Comments:** Memorial – bones taken from Chamkar Svay + Chamkar Mensah burial sites + Wat Phnom Chan

**Latitude:** N 11°54'46" **Longitude:** E 105° 39'19"

**File No:** R022103A **Time:** 1040

# CGP SITE FORM

Site Name: Salam Suong  Khmer: ..................  ID No. 031604  Date: 21/2/96

Province: K-Cham  District: Tbong Khmum
Sub-District: Suong  Village: Suong  Khmer: ...

**Prison** (circled)
- __ Interrog Ctr.
- __ Previous Prison
- __ Purpose Built
- ✓ School
- __ Wat
- __ House
- __ Other

**Burial Site**
- __ Pit
- __ Kiln
- __ Rice paddy
- __ River/lake
- __ Well
- __ Execution
- __ Other

**Memorial**
- __ Wat
- __ Stupa
- __ Brick/tile
- __ Wooden
- __ Other

**Access:**

Route No......... .........Km from ..........................Condition ...................

Route No......... .........Km from ..........................Condition...................

**Estimated No of Victims** ............................... **Mass graves**..................

**Contact Persons (Official)** Deputy Chief of Commune - Wa Phar

**Visited:** Yes (circled) / No  **Team:** CB/HS

**Photos:** Roll # 2  Shots # 6-8

**Documents:**.......................................................................

**Interviews:** Hoy Sok (prisoner)

**Comments:** Secondary School Suong used as prison.

**Latitude:** N. 11°54'57"  **Longitude:** E. 105°39'30"

**File No:** R022103B  **Time:** 1100

# CGP SITE FORM

Site Name: Chamkar Menoah Khmer.................... ID No. 03/b.05
Date: 21/2/96

Province: K-Cham District: Kbong Khmum
Sub-District: Suong Village: Rubber Plantation Khmer.................

**Prison**
__Interrog Ctr.
__Previous Prison
__Purpose Built
__School
__Wat
__House
__Other

**Burial Site** (circled)
__Pit
__Kiln
__Rice paddy
__River/lake
✓__Well (2)
__Execution
__Other

**Memorial**
__Wat
__Stupa
__Brick/tile
__Wooden
__Other

**Access:**
Route No......... .........Km from ..........................Condition .....................

Route No......... 5 Km from DHQ Condition good.

**Estimated No of Victims** 1000 + **Mass graves** 2

**Contact Persons (Official)** ..................................................

**Visited:** (Yes) No **Team :** CB/HS

**Photos:** Roll # 2 Shots # 9 - 11

**Documents:**..................................................

**Interviews:**..................................................

**Comments:** 2 deep wells (10m+) in rubber plantation North of Suong were used as execution & burial sites for hundreds of mainly Lon Nol soldiers in 1975-1976. (baskets + knives put in 1 house) Brought by horse carts

**Latitude:** N 11°56'58" **Longitude:** E 105°38'58.5"

**File No:** R022 104 A **Time:** 1130

# CGP SITE FORM

ID No. 030301

Site Name Wat Skoun Khmer.................. Date 22/2/96

Province K Cham District ~~Prey~~ Cheung Prey
Sub-District So Tep Village Skoun Khmer..................

| Prison | Burial Site | Memorial (circled) |
|---|---|---|
| __Interrog Ctr. | __Pit | __Wat |
| __Previous Prison | __Kiln | ✓ Stupa |
| __Purpose Built | __Rice paddy | __Brick/tile |
| __School | __River/lake | __Wooden |
| __Wat | __Well | __Other |
| __House | __Execution | |
| __Other | __Other | |

**Access:**
Route No 7 45 Km from K-Cham Condition Good

Route No......... .........Km from ..........................Condition......................

**Estimated No of Victims** ................................**Mass graves**..................

**Contact Persons (Official)** ..................................................................

**Visited:** (Yes) / No **Team :** CB/HE

**Photos:** Roll # 2 Shots # 18

**Documents:**..................................................................

**Interviews:**..................................................................

**Comments:** Elaborate Stupa at Wat built by local people for bones excavated nearby.
Region Chief of Santesok - Kao Park

**Latitude:** N 12°03'42" **Longitude:** E 105°09'20.5"

**File No:** R022202A **Time:** 0935

# CGP SITE FORM

ID No. 030303

Site Name Day Taprang Khmer.................. Date 22/2/96

Province K-Cham District Cheung Prey
Sub-District So Tup Village Bana Khmer

| Prison | Burial Site | Memorial |
|---|---|---|
| __Interrog Ctr. | ✓ Pit | __Wat |
| __Previous Prison | __Kiln | __Stupa |
| __Purpose Built | __Rice paddy | __Brick/tile |
| __School | __River/lake | __Wooden |
| __Wat | __Well | __Other |
| __House | __Execution | |
| __Other | __Other | |

**Access:**
Route No. 7 50 Km from K Cham Condition ..................
Route No......... .........Km from ..........................Condition....................

**Estimated No of Victims** 2,000 + **Mass graves** 100 +

**Contact Persons (Official)** Chek Kouan Chief of Cult & Religion
Ouch Im Culture & Art.

**Visited:** (Yes)/ No **Team :**..................................................

**Photos:** Roll # ............ Shots # 24, 25

**Documents:**..........................................................................

**Interviews:** Depty of Cult & Religion Chet Choen -

**Comments:** Many mass graves behind school on Hwy 7. Brought by truck
Bones & Clothing & rags scattered on ground
Pol Pot officials — chief of village etc 1977-78

**Latitude:** N 12°03'25" **Longitude:** E 105°03'44"

**File No:** R022203A **Time:** 1030

# CGP SITE FORM

ID No. 030304

Site Name Law Thuong Khmer ... Date 22/2/96

Province K Cham District Cheung Prey

Sub-District Knao Dambong Village Rotieng Khmer ...

| Prison (circled) | Burial Site | Memorial |
|---|---|---|
| __Interrog Ctr. | __Pit | __Wat |
| __Previous Prison | __Kiln | __Stupa |
| ✓ Purpose Built | __Rice paddy | __Brick/tile |
| __School | __River/lake | __Wooden |
| __Wat | __Well | __Other |
| __House | __Execution | |
| __Other | __Other | |

Built 1974 for Lon Nol soldiers

**Access:**

Route No. 7 60 Km from K Cham Condition Good

Route No......... .........Km from ......................... Condition.......................

**Estimated No of Victims** ......................... **Mass graves**..................

**Contact Persons (Official)** ..................................................

**Visited:** (Yes) / No **Team :** CB/HS

**Photos:** Roll # ............ Shots # ..................................

**Documents:**..................................................

Interviews: Chek Chuon, Chief of cult + religion

**Comments:** One large prison + many 1976 Santesok buildings made of bamboo + palm leaf. Witness saw many prisoners – two lines facing (one ♀ one ♂) with shackles around thighs sitting. Hands tied behind back.

Prison chief – Hang Deputy – Chun

**Latitude:** N 12°02'55" **Longitude:** E 105°01'33"

**File No:** R0222038 **Time:** 1055

# CGP SITE FORM

ID No. 030305

Site Name Law Thuong Khmer

Date 22/2/96

Province K-Cham District Cheung Prey

Sub-District Khao Dambong Village Rovieng Khmer

**Prison** (circled and struck through)
- __Interrog Ctr.
- __Previous Prison
- __Purpose Built
- __School
- __Wat
- __House
- __Other

**Burial Site** (circled)
- ✓ Pit
- __Kiln
- __Rice paddy
- __River/lake
- __Well
- __Execution
- __Other

**Memorial**
- __Wat
- __Stupa
- __Brick/tile
- __Wooden
- __Other

**Access:**

Route No. 7 72 Km from PNP Condition Good

Route No. 7 5 Km from DHQ Condition

500 m S. of Hwy 7 2k W of shell station

**Estimated No of Victims** **Mass graves** 200+

Pits 2m deep

**Contact Persons (Official)** Chief of Cult & Religion DHQ.

**Visited:** Yes / No **Team :** CB/HS

**Photos:** Roll # 2 Shots # 26-28

**Documents:**

**Interviews:** OK Vanarith a Hun Hean (Ms) ~~[illegible]~~

**Comments:** Many burial pits found by woodcutter. Many bones scattered & clothing in ground. V. important site not known by DHQ. Similar site 200 m to West of this site & all around prison.

**Latitude:** N 12°02'44.5" **Longitude:** E 105°01'42.5"

**File No:** R022204A **Time:** 1110

# CGP SITE FORM

ID No. 030601
Date 19.10.95

Site Name Wat No Kor Khmer ᨾᨾ

Province K-Cham
District Kampong Siem
Sub-District Ampil
Village Ampil Leu Khmer ᨾᨾ

**Prison**
__Interrog Ctr.
__Previous Prison
__Purpose Built
__School
__Wat
__House
__Other

**Burial Site**
__Pit
__Kiln
__Rice paddy
__River/lake
__Well
__Execution
__Other

**Memorial** (circled) ~~196~~ 1989
__Wat
✓ Stupa
✓ Brick/tile
__Wooden
__Other

**Access:**
Route No 7 5 Km from K-Cham Condition
Route No Km from Condition

**Estimated No of Victims** ~~[illegible]~~ 1,000+ **Mass graves**

**Contact Persons (Official)** Chief of Wopotor

**Visited:** (Yes) No **Team :** CB/HJ/HS

**Photos:** Roll # 2 Shots # 16-21

**Documents:**

**Interviews:**

**Comments:** Two memorials at Wat, one for ~~a~~ storage another stupa for ceremonies. (20 May each year)

**Latitude:** N 12°00'03" **Longitude:** E 105°26'23"

**File No:** R101901A **Time:** 0840

# CGP SITE FORM

ID No. 030602

Site Name Wat Phnom Proh Khmer ....

Date 19.10.95

Province K - Cham

District Kampong Siem

Sub-District Kodak

Village Tro Peang Cha Khmer [illegible]

**Prison** (circled)
- __ Interrog Ctr.
- __ Previous Prison
- __ Purpose Built
- __ School
- ✓ Wat
- __ House
- __ Other

**Burial Site** (circled)
- ✓ Pit
- __ Kiln
- __ Rice paddy
- __ River/lake
- __ Well
- ✓ Execution
- __ Other

**Memorial** (circled)
- __ Wat
- __ Stupa
- __ Brick/tile
- __ Wooden
- ✓ Other Kitchen of Monks

**Access:**

Route No. 7 7 Km from K - Cham Condition Good

Route No. ........ ........Km from ........ Condition ........

**Estimated No of Victims** 10,000 + **Mass graves** 47 large many more small.

**Contact Persons (Official)** Chief of Wapater

**Visited:** Yes (circled) / No **Team :** CB/HJ/HS

**Photos:** Roll # 2 Shots # 30 - 36

**Documents:** Mr Riep } Mr Chhunn } Chiefs of Prison. Chhunn killed himself in 1978 from 41, 42, 43 regions to killers

**Interviews:** ........

**Comments:** Bones moved from this memorial to Wat Nokor because of tourists. Wat used as prison, Hot as Pol Pot Office Tree used to bash children's brains out near pits.

**Latitude:** N 12° 01' 42" **Longitude:** E 105° 24' 59"

**File No:** R101902A **Time:** 0925

# របាយការណ៍ស្តីអំពីការប្រល័យពូជសាសន៍ នៅខេត្តកំពង់ចាម

## ចុះពិនិត្យទីតាំងដោយក្រុមគូរផែនទី

## " ១៧-១៩ ខែតុលា ឆ្នាំ១៩៩៥ " " ២០-២២ ខែកុម្ភៈ ឆ្នាំ១៩៩៦ "

**ស្រាវជ្រាវដោយ : ឆាលីស ឋឹរង់, ហេឡែន ចាវីស, ហាក់ សុផល**

**ថ្ងៃអង្គារ៍ ទី១៧ ខែតុលា**

យើងបានមកដល់សាលាខេត្តកំពង់ចាមនៅម៉ោង ១១:១៥នាទី ព្រឹក ។ អង្គប្រជុំត្រូវបានរៀបចំឡើងដោយលោកអភិបាលខេត្ត និងមន្ត្រីចំណុះខេត្ត នៅម៉ោង ៣រសៀល ។

ការប្រជុំត្រូវបានប្រព្រឹត្តទៅនៅក្នុងការិយាល័យរបស់លោកអភិបាលខេត្ត **ហ៊ុន ណេង** ហើយ ត្រូវបានចូលរួមដោយអ្នកបកប្រែ អ្នកថតរូប និងមន្ត្រីមួយចំនួនរបស់លោក ដូចជាលោក **ខួន វ៉ាន់ពន្លឺ** ជាប្រធានមន្ទីរធម្មការ និងសាសនា លោក **កើត ចាន់** ជាអនុប្រធានមន្ទីរវប្បធម៌ និងសិល្បៈ ។ល។

ការចុះស្រាវជ្រាវទីតាំងប្រល័យពូជសាសន៍ ត្រូវបានកំណត់រយៈពេល ២ថ្ងៃ ។ ទីតាំងសំខាន់ៗនៅស្រុកក្រូចឆ្មារ គឺអាចធ្វើដំណើរទៅបានតាមទូកតែប៉ុណ្ណោះ ។ យើងបានសុំអោយលោកអភិបាលខេត្តជួយរកទូកល្បឿន សំរាប់ធ្វើដំណើរក្នុងរយៈពេល ១ថ្ងៃ ។

ការធ្វើដំណើររបស់យើងតាមផ្លូវទឹក ត្រូវបានរួមដំណើរដោយលោក **អ៊ី សាហាក់** ដែលជាអភិបាលស្រុកក្រូចឆ្មារ ហើយយើងបានសំរេចចិត្តចុះត្រួតពិនិត្យទីតាំង ២កន្លែង ក្នុងស្រុករបស់គាត់ នៅពេលព្រឹក ហើយទីតាំងមួយទៀត នៅក្នុងស្រុកស្ទឹងត្រង់ ពេលដែលធ្វើដំណើរត្រឡប់មកវិញនៅថ្ងៃរសៀល ។

ការថតវីដេអូ បានថតនៅពេលដែលការប្រជុំជាមួយលោកអភិបាលខេត្តបានកំពុងតែប្រព្រឹត្តិទៅ ហើយក្នុងពេលនោះដែលយើងស្មានថាគ្រាន់ជាការថតទុកជាឯកសារសំរាប់លោកអភិបាលខេត្តផ្ទាល់ ក្នុង ពេលជាមួយគ្នានោះដែរ យើងបានគិតហើយធ្វើការបញ្ជាក់ច្បាស់ថា យើងមិនចង់អោយមានការបញ្ចាំង ក្នុងទូរទស្សន៍ទេ ពីព្រោះដើម្បីការពារនូវសុវត្ថិភាព តែគួរអោយស្តាយ ការប្រជុំរបស់យើងត្រូវបានបង្ហាញយ៉ាងច្បាស់នៅក្នុងកញ្ចក់ទូរទស្សន៍នៅក្នុងខេត្ត និងក្នុងប្រទេស ។

**<u>ថ្ងៃពុធ ទី១៨ ខែតុលា</u>**

យើងបានចេញដំណើរពីផែកំពង់ចាម នៅម៉ោង ៧:៤៥នាទីព្រឹក តាមកាណូត ។ ដើម្បីការពារសុវត្ថិភាព យើងត្រូវបានអមដំណើរដោយលោក **កើត ឆាំត** ជាអនុប្រធានមន្ទីរវប្បធម៌ និងសិល្បៈ អភិបាលស្រុកក្រូចឆ្មារ ហើយនិងប៉ូលីស ៤នាក់ទៀត ។ យើងបានមកដល់ទីតាំងមួយដែលមានចម្ងាយ ៤០គីឡូម៉ែត្រ ពីទីរួមខេត្តកំពង់ចាម រយៈពេលធ្វើដំណើរជិតមួយម៉ោង តាមទន្លេមេគង្គ បញ្ច្រាស់ទឹកទៅលើ ។

## ទីតាំងប្រល័យពូជសាសន៍

ទ្រាទី២ ភូមិទ្រាទី២ ឃុំទ្រា ស្រុកក្រូចឆ្មារ

ភូមិទ្រាទី២ ជាភូមិមួយក្នុងចំណោមភូមិទាំង៥ របស់ប្រជាជនចាម ក្នុងស្រុកក្រូចឆ្មារ ដែលត្រូវបានពួកខ្មែរក្រហមជំលៀសចេញ និងបំផ្លិចបំផ្លាញ ក្នុងសម័យ **ប៉ុល ពត** ប្រជាជនចាមទាំងអស់ត្រូវបានផ្លាស់ប្តូរទីកន្លែង ឬ យកទៅសម្លាប់ ។ នៅភូមិទ្រាទី២នេះ យើងត្រូវបានបង្ហាញអំពីឆ្អឹងសាកសពមួយ ចំនួនដែលបានលយចេញពីរណ្តៅសាកសព ២រណ្តៅ ក្នុងចំណោមរណ្តៅទាំង៥ ក្បែរមាត់ច្រាំងទន្លេមេគង្គ រណ្តៅ ៣ ដទៃទៀតត្រូវបានកប់នៅក្រោមដើមក្រូចឆ្មារ ជិតនោះដែរ ហើយរណ្តៅទាំង៣នោះ ពុំទាន់ បានគាស់ នៅឡើយ ។ មានផ្ទះចំនួន ៣ខ្នង ដែលត្រូវបានពួកខ្មែរក្រហមយកមកប្រើធ្វើជាមន្ទីរឃុំឃាំង និងសំរាប់ពួកកម្មាភិបាលសន្តិសុខរស់នៅ ។

សាក្សីម្នាក់បានរាយការណ៍ថា ពួកខ្មែរក្រហមបានដឹកប្រជាជនតាមទូកមកពីខាងលើ នៃទន្លេមេគង្គមកសម្លាប់នៅទីនេះ ។ សាក្សីជាជនជាតិចាម ២នាក់ បានមានប្រសាសន៍ថា ស្ពានទាំងអស់ដែលឆ្លងកាត់មកកាន់ទីនេះត្រូវបានកាត់ផ្តាច់ លើកលែងតែស្ពានមួយគត់សំរាប់ឆ្លងកាត់ក្នុងភូមិ ។ គ្មានប្រជាជនណាម្នាក់ត្រូវបានអនុញ្ញាតិអោយឆ្លងកាត់ក្នុងតំបន់ហាមឃាត់នេះទេ ។

ពួកខ្មែរក្រហមបានចាក់មេក្រូបំពងសំលេងពីម៉ោង ៦ល្ងាច ដល់ម៉ោង ៩យប់ ដើម្បីបន្ទប់សំរែកជនរងគ្រោះ ដែលត្រូវពួកវាសម្លាប់ ។ សាក្សីបានបញ្ជាក់ទៀតថា ជនរងគ្រោះត្រូវបានសម្លាប់ដោយត្បូងចបវាយក្បាលពីខាងក្រោយ ចំណែកកូនក្មេងត្រូវបានពួកវាចាប់ជើងបោកក្បាលទៅនឹងដើមឈើ ។

ក្នុងតំបន់នេះប្តីប្រពន្ធត្រូវបានពួកខ្មែរក្រហម បំបែកអោយនៅផ្សេងពីគ្នា ដោយប្រាប់ថាអោយទៅធ្វើការនៅតំបន់ផ្សេងងាយស្រួលរស់នៅជាង ចំណែកប្រពន្ធ និងកូនត្រូវបានបញ្ជូនអោយទៅរស់នៅក្នុងភូមិចាមផ្សេងទៀត ។

ព្រះវិហារ និងសាលារៀន របស់ជនជាតិចាម ក្នុងឃុំទ្រា ត្រូវបានសាងសង់ឡើងវិញ ដោយមានការឧបត្ថម្ភពីរដ្ឋាភិបាលម៉ាឡេស៊ី ។

## ទីតាំងប្រល័យពូជសាសន៍

កោះផល ភូមិកោះផល ឃុំប៉ឺស១ ស្រុកក្រូចឆ្មារ

ភូមិកោះផល គ្រាន់តែបានពិពណ៌នា នូវការសម្លាប់មួយក្នុងតំបន់នោះ នាសម័យ **ប៉ុល ពត** ប៉ុណ្ណោះ ។ រណ្តៅសាកសព ចំនួន ៤៩ ត្រូវបានបង្ហាញអោយឃើញរណ្តៅនីមួយៗមានទំហំ ២ម៉ែត្រ គុណនឹង ៤ម៉ែត្រ ដែលស្ថិតនៅជិតភូមិក្នុងព្រៃឫស្សី មានរណ្តៅតែ ២ប៉ុណ្ណោះ ដែលត្រូវបានគាស់យកសាកសព សាក្សីបានបំភ្លឺថា មន្ទីរឃុំឃាំងរយៈពេលខ្លីមួយ ដែលបានសង់ឡើងក្នុងសម័យ **ប៉ុល ពត** ក្នុងចំណោម អាគារទាំង៣ មកទល់បច្ចុប្បន្ននេះ នៅសល់តែអាគារមួយប៉ុណ្ណោះ អាគារ ២ខ្នងដទៃទៀត សង់ឡើង ដើម្បីផ្ទុកសំភារៈ និងជាបន្ទាយយោធា ។

អ្នកទោសទាំងអស់ត្រូវបានពួកខ្មែរក្រហមនាំមកពីត្រើយម្ខាង ទន្លេមេគង្គ និងពីខាងលើខ្សែទឹក (ក្រចេះ?) ហើយត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំងមួយយប់ បន្ទាប់មកយកទៅកាន់រណ្តៅព្រៃឫស្សី ដើម្បីសម្លាប់ ។

សាក្សីដែលជាអ្នកនេសាទត្រី ដែលបានរស់នៅក្នុងតំបន់នោះ បានរាយការណ៍បន្តទៀតថា គាត់បានឮសម្រែករបស់អ្នកទោស នៅពេលយប់ ក្នុងខណៈដែលគាត់កំពុងតែនេសាទត្រី ហើយគាត់បានឃើញទូកជាច្រើនដែលផ្ទុកទៅដោយជនរងគ្រោះ ឆ្ពោះមកកាន់មន្ទីរឃុំឃាំងជារៀងរាល់ថ្ងៃ ។ សាក្សីគឺជាអ្នកនេសាទត្រីនៅទីនោះ ក្នុងរយៈពេលតែ៣ខែ នារដូវប្រាំង ក្នុងឆ្នាំ១៩៧៧ ។ យោងតាមការសន្និដ្ឋាន ចំនួនមនុស្សស្លាប់នៅទីនោះប្រហែលពី ៥១០.០០០ ហើយភាគច្រើនជាជនជាតិចាម ។

## ទីតាំងប្រល័យពូជសាសន៍

វត្តស្ទឹងត្រង់ ភូមិព្រៃបារាំង ឃុំព្រែកកោះ ស្រុកស្ទឹងត្រង់

យើងត្រូវបានជូនដំណើរទៅកាន់ក្រោយវត្ត ហើយត្រូវបានបង្ហាញអោយឃើញសារមន្ទីរបាក់បែកមួយ ដែលសង់អំពីឈើ បំណែកឈើបាក់បែកបានដួលរលំលើក្បាល និងឆ្អឹងសាកសពរាប់រយ ហើយព្រៃស្បាតបានដុះគ្របដណ្តប់ពីលើពំនូកឆ្អឹងនោះទៀតផង ។

នៅជិតនោះដែរ មានរណ្តៅសាកសពជាង ២០រណ្តៅ និងនៅមានសេសសល់បំណែកឆ្អឹង និងចំណែកខោអាវរបស់សាកសពនៅលើដីផងដែរ ។ លោកអភិបាលស្រុកបានមានប្រសាសន៍ថានៅមានរណ្តៅសាកសពធំៗចំនួន ៧ទៀត នៅចម្ងាយ ១គីឡូម៉ែត្រ ពីទីនេះ ។ វិហារក្នុងវត្តស្ទឹងត្រង់ប្រហែលជាត្រូវបានប្រើធ្វើជាមន្ទីរឃុំឃាំងសំរាប់អ្នកទោស ដែលត្រូវបានសម្លាប់ នៅទីតាំងប្រល័យពូជសាសន៍

ក្រោយវត្តនេះ តែសាក្សីម្នាក់ដែលបានរួចខ្លួននៅពេលដែល ពួកខ្មែរក្រហមយកគាត់មកសម្លាប់នៅទីនេះ តែនៅពេលនេះ គាត់ពុំបាននៅនិយាយប្រាប់យើងបាន ។

## ថ្ងៃព្រហស្បតិ៍ ទី១៩ ខែតុលា

ការប្រជុំមួយត្រូវរៀបចំឡើងនៅម៉ោង៧:៣០នាទី ព្រឹក ដោយប្រធានមន្ទីរធម្មការ និងសាសនា **ខួន ទាំងពន្លឺ** នៅការិយាល័យរបស់គាត់ផ្ទាល់ ស្តីអំពីការចុះត្រួតពិនិត្យទីតាំងមួយចំនួននៅស្រុកកំពង់សៀម ។ ក្នុងពេលនោះយើងក៏បានធ្វើការសំរេចចិត្តចុងក្រោយក្នុងការចុះទីតាំងប្រល័យពូជសាសន៍ នៅថ្ងៃទី២ របស់យើង ។

## អំពីសារមន្ទីរ

វត្តនគរ ភូមិអំពិលលើ ឃុំអំពិល ស្រុកកំពង់សៀម

វត្តនេះមានទីតាំងនៅជិតផ្លូវជាតិលេខ៧ ពីកំពង់ចាមទៅភ្នំពេញ ហើយនៅមិនឆ្ងាយប៉ុន្មានពីទីរួមខេត្តកំពង់ចាមទេ ។ នៅក្នុងបរិវេណវត្តមានប្រាសាទបុរាណមួយសង់ឡើងផ្ទាល់ដី ដែលមានបែបផែនដូចជាប្រាសាទអង្គរដែរ ។ នៅក្នុងវត្តមានសារមន្ទីរ ២កន្លែង ដែលបានតំកល់ទុកឆ្អឹងសាកសព ហើយឆ្អឹងសាកសពទាំងនោះមួយចំនួន ត្រូវបាននាំមកពីរណ្តៅសាកសពវត្តភ្នំប្រុស ដែលមានចម្ងាយ ៤គីឡូម៉ែត្រពីវត្ត តាមបណ្តោយផ្លូវជាតិដដែលនោះ ឆ្ពោះទៅក្រុងភ្នំពេញ ។ សារមន្ទីរមួយត្រូវបានតម្កល់ឆ្អឹងសាកសពជាបណ្តោះអាសន្នក្នុងផ្ទះធ្វើពីបេតុង រីឯមួយទៀតនៅក្នុងចេតិយ៍ទុកសំរាប់ធ្វើពិធីបុណ្យរំលឹក ។

សារមន្ទីរទាំងនេះមានចំនួនសាកសព ជាង ១000នាក់ ។

## ទីតាំងប្រល័យពូជសាសន៍

វត្តភ្នំប្រុស ភូមិត្រពាំងចារ ឃុំក្រឡ ស្រុកកំពង់សៀម

ចម្ងាយ៤គីឡូម៉ែត្របន្តទៅមុខទៀត តាមបណ្តោយផ្លូវជាតិលេខ៧ ឆ្ពោះទៅកាន់ទីក្រុងភ្នំពេញ ។

វត្តភ្នំប្រុស ជាវត្តមួយដ៏ល្អប្រណិត ដែលត្រូវបានសង់ឡើងកំពូលនៃកូនភ្នំមួយ ដាច់ស្រឡះពីភូមិប្រជាជន ។ យើងអាចមើលឃើញយ៉ាងច្បាស់ពីថ្នល់ជាតិលេខ៧ ហើយនៅជិតនោះដែរមានវត្តមួយទៀតដែលមានទ្រង់ទ្រាយដូចគ្នាបេះបិទ គឺវត្តភ្នំស្រី ។ វត្តភ្នំប្រុស ត្រូវបានពួកខ្មែរក្រហមប្រើប្រាស់ធ្វើជាមន្ទីរឃុំឃាំង ហើយនៅពីខាងជើងវត្តភ្នំប្រុស ក្នុងចន្លោះវត្តទាំងពីរ មានរណ្តៅសាកសពធំៗចំនួន ៤៧រណ្តៅ ហើយនិងរណ្តៅតូចៗជាច្រើនទៀត ។ ទីតាំងនេះ បើមិនមែនជាគុកតំបន់ ក៏ជាភូមិភាគតាមការសន្និដ្ឋានមានចំនួនមនុស្សជាង ១០.000នាក់ ដែលត្រូវបានយកមកសម្លាប់នៅទីនេះ ។ រណ្តៅសាកសពភាគច្រើន

ត្រូវបានគាស់បំផ្លាញ ហើយឆ្អឹងសាកសពត្រូវបានរាយប៉ាយ ។ មានឆ្អឹងសាកសពមួយចំនួនត្រូវបានតំកល់ទុកក្នុងអាគារចាស់មួយ ដែលពីមុនជាផ្ទះបាយរបស់ព្រះសង្ឃ និងយាយជីតាំងសមាធិ តែដោយមានការជ្រៀតជ្រែកពីអ្នកដែលទៅមើល ឆ្អឹងមួយចំនួនធំ ក៏ត្រូវបានដឹកជញ្ជូនទៅកាន់វត្តនគរ ។

សាក្សីម្នាក់បានចង្អុលបង្ហាញដើមឈើមួយដើម ជិតរណ្តៅសាកសពដែលពួកខ្មែរក្រហមយកកូនក្មេងមកបោកសម្លាប់ ។ ក្រោយថ្ងៃរំដោះគាត់បានឃើញមានខួរ ឈាម និងសក់នៅជាប់សំបកដើមឈើ ។

សាក្សីឈ្មោះ **ខង សុផាលី** បានរាយការណ៍ថា បងស្រីបានឃើញម្តាយរបស់គាត់ត្រូវបានពួកពេទ្យខ្មែរក្រហមចាក់ថ្នាំសម្លាប់នៅក្នុងមន្ទីរពេទ្យ ដែលនៅជិតវត្តភ្នំប្រុស ក្នុងពេលជាមួយនោះដែរ រូបបងស្រីផ្ទាល់បានសំរាកក្នុងមន្ទីរពេទ្យនោះដែរ ។

បងស្រីបានរត់គេចចេញពីមន្ទីរពេទ្យនៅពេលយប់ជាមួយប្អូនប្រុសពៅរបស់គាត់ មានសន្តិសុខម្នាក់បានដេញតាមចាប់គាត់ តែសំណាងល្អដោយមានខ្មែរក្រហមម្នាក់ ដែលជាប្រធានជនពិការយាមសាកសពដែលមានចិត្តសប្បុរសជួយគាត់ ដោយយកគាត់ទៅលាក់ទុកនៅលើដំបូលវិហារវត្តភ្នំប្រុស ចំនួន៣ថ្ងៃ ក្រោយមកប្រធានអ្នកយាមសាកសពឈ្មោះសមមិត្ត **ជឿន** នោះបានចាត់ចែងបញ្ជូនគាត់គេចទៅនៅជនបទតាមរថយន្តដឹកទំនិញដោយមានសមមិត្ត **អង់ គីមអេង** ជាអ្នកបើកបរ ដែលបច្ចុប្បន្នត្រូវជាប្តីរបស់គាត់ ។

ប្អូនប្រុស បងស្រី ២នាក់ និងឪពុកម្តាយរបស់គាត់ត្រូវបានសម្លាប់ដោយពួកខ្មែរក្រហម ។ គាត់បាននិយាយប្រាប់យើងដោយខ្សឹបខ្សួល ។ ប្រធានយាមសាកសពឈ្មោះ **ជឿន** ដែលបានជួយសង្គ្រោះជីវិតគាត់ត្រូវបានស្លាប់ដោយចូលក្នុងកង់រថក្រោះរបស់កងទ័ពវៀតណាមកំពង់បើក ទាំងដៃទាំងពីរជាប់ចំណងទៅក្រោយ បន្ទាប់ពីថ្ងៃរំដោះ ។

## <u>សេចក្តីសន្និដ្ឋាន</u>

ការចុះពិនិត្យទីតាំងរបស់យើងនៅខេត្តកំពង់ចាម ត្រូវបានទទួលជោគជ័យ ពីព្រោះមានចំណុចសំខាន់ ២យ៉ាង មួយគឺយើងបានឃើញភស្តុតាងរណ្តៅសាកសព របស់ប្រជាជនចាម នៅស្រុកក្រូចឆ្មារ ហើយភស្តុតាងមួយទៀត គឺនៅទីតាំងប្រល័យពូជសាសន៍ និងមន្ទីរឃុំឃាំងវត្តភ្នំប្រុស និងវត្តស្ទឹងត្រង់ ។

ទំហំ និងវិសាលភាព នៃរណ្តៅសាកសពនៅវត្តភ្នំប្រុស អាចបញ្ជាក់បានថាជាការសម្លាប់ដ៏ធំមួយ ក្នុងតំបន់ជុំវិញខេត្តកំពង់ចាម ។

## ថ្ងៃអង្គារ៍ ទី២០ ខែកុម្ភៈ ឆ្នាំ១៩៩៦

ចំពោះការវិលត្រឡប់របស់ក្រុមផែនទី មកកាន់ខេត្តកំពង់ចាម ចំពេលដែលត្រូវប្រឈមមុខចំពោះរដូវប្រាំង នៅក្នុងខេត្តនោះដែរ ។

ដំបូងយើងបានធ្វើការទំនាក់ទំនងជាមួយលោក **ខួន វ៉ាន់ពន្លឺ** ជាប្រធានមន្ទីរធម្មការ និងសាសនា ។ នៅពេលនោះគាត់បានផ្តល់ពតិមានទៅកាន់សាលាស្រុកកងមាស ដើម្បីអោយការិយាល័យស្រុកនោះដឹងជាមុនថា យើងនឹងមកដល់ទីនោះនៅថ្ងៃរសៀលនោះ ដើម្បីពិនិត្យទីតាំង ។

យើងត្រូវបានជូនដំណើរក្នុងការចុះពិនិត្យរបស់យើង ដោយលោក **និន ស៊ីណាត** ជាប្រធានការិយាល័យធម្មការ និងសាសនាខេត្ត ។

បន្ទាប់ពីបានធ្វើដំណើរចម្ងាយ ៣០គីឡូម៉ែត្រ ប៉ែកខាងលិច ទីរួមខេត្តកំពង់ចាម តាមបណ្តោយផ្លូវជាតិលេខ ៧ មក យើងក៏បានបត់មកទិសខាងត្បូង ហើយបើកបរអស់ចម្ងាយ ១៥គីឡូម៉ែត្រ ឆ្ពោះទៅកាន់ទន្លេមេគង្គ ដែលជាទីតាំងរបស់សាលាស្រុកកងមាស ។ នៅទីនោះយើងបានជួប អនុអភិបាលស្រុក គឺ លោក **អុំ វណ្ណថា** ដែលជាអ្នកប្រគល់ឯកសារចងក្រងអោយយើង ហើយថែមទាំងបានបោះត្រាលើ ឯកសារ ដែលស្តីអំពីបញ្ជីរាយនាមនូវទីតាំងប្រល័យពូជសាសន៍ទាំងអស់ដែលមាននៅក្នុងស្រុក ដែលត្រូវ បានចងក្រងឡើង កាលពីព្រឹកនោះ ។ បន្ទាប់មកយើងក៏បានជ្រើសរើសយកទីតាំងធំបំផុតពីកន្លែង ដើម្បី ចុះពិនិត្យនៅថ្ងៃរសៀលនោះ ។

## ទីតាំងស្រុកកងមាស

## វត្តអូរត្រកួន ឃុំពាមជីកង

វត្តនេះ និងសាលារៀន ដែលនៅជិតនោះដែរ ត្រូវបានប្រើធ្វើជាមន្ទីរឃុំឃាំងដ៏សំខាន់របស់ស្រុកនាឆ្នាំ១៩៧៤-៧៨ ។ មុនដំបូងជនរងគ្រោះដែលជាទាហានរបស់ **លន់ ណុល** ដែលត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំង និងសម្លាប់នៅទីនោះ ហើយបន្ទាប់មកគឺជាប្រជាជនថ្មីដែលត្រូវបានជំលៀសពីទីក្រុងភ្នំពេញមកកាន់ស្រុកកងមាស ។

ជនរងគ្រោះទាំងអស់ ដែលត្រូវបានសម្លាប់នៅឯរណ្តៅសាកសពដែលនៅក្បែរវត្តនោះ គឺត្រូវបានពួកវានាំមកតាមទូក និងតាមរទេះសេះ ។

យោងតាមការបញ្ជាក់នៅក្នុងឯកសារដែលទទួលបានពីសាលាស្រុក ឃើញថាមានរណ្តៅសាកសព ចំនួន ៤៦៧ ហើយតាមការប៉ាន់ស្មាននូវចំនួនជនរងគ្រោះដែលបានសម្លាប់នៅទីនោះ គឺមានចំនួន ៣២.៦៩០ ។ រណ្តៅសាកសពទាំងនេះ មួយចំនួនត្រូវបានគាស់រួចហើយឆ្អឹងសាកសពទាំងនោះត្រូវបាន ទុកនៅក្នុងវិមានសព ក្នុងវត្តនោះ ។

**វត្តនិគ្រោធ កងមាស ០៣០៧០៤/៥**

វត្តនេះត្រូវបានប្រើធ្វើជាមន្ទីរឃុំឃាំងតាំងពីឆ្នាំ១៩៧០ ប្រជាជនថ្មីត្រូវបានសុំអោយមកកាន់វត្ត ដើម្បីទទួលម្ហូបអាហារ ដោយពួកខ្មែរក្រហម ហើយបន្ទាប់មកត្រូវបានដាក់ក្នុងបន្ទប់ឃុំឃាំង ព្រមទាំងត្រូវបានសម្លាប់ទៀតផង ។ វត្តនេះ គឺជាមន្ទីរឃុំឃាំងតំបន់ ក្នុងតំបន់ ៤១ ហើយត្រូវបានប្រើតាំងពីឆ្នាំ ១៩៧៥-៧៦ នៅពេលត្រូវបានផ្លាស់ប្តូរកន្លែងទៅកាន់វត្តអូរត្រកួន ។

ព្រះសង្ឃដែលគង់នៅវត្តនោះ បានរាយការណ៍ថា បានឃើញឈ្មោះជាច្រើនដែលសរសេរដោយឈាមនៅលើជញ្ជាំងវិហារ ក្នុងវត្តនោះ តែឥឡូវឈ្មោះទាំងនោះត្រូវបានលាបពណ៌ពីលើ លើកលែងតែឈ្មោះមួយនៅក្នុងតារាង ( គុំ នី លេខ៣) ។ ចំនួនរណ្តៅសាកសពដែលបានផ្តល់ពីរបាយការណ៍របស់ស្រុក បានអោយដឹងថាមាន ១៨៦រណ្តៅ ហើយចំនួនជនរងគ្រោះដែលបានប៉ាន់ស្មាន មានចំនួន ១១.១៦០ ដែល ត្រូវបានសម្លាប់នៅទីតាំងនេះ ។

## ថ្ងៃពុធ ទី២១ ខែកុម្ភៈ ឆ្នាំ១៩៩៦

នៅព្រឹកព្រលឹមថ្ងៃបន្ទាប់យើងបានឆ្លងសាឡាង កាត់តាមទន្លេមេគង្គពីទីរួមខេត្តកំពង់ចាមទៅកាន់ទន្លេបិទ ។ កំពង់ផែ ដែលឆ្ពោះទៅទិសបូព៌ា នៃទន្លេគឺជាស្រុកត្បូងឃ្មុំ ។ យើងត្រូវបានជូនដំណើរដោយលោក **និត ស៊ីណាត** និងប៉ូលីសការពារមកពីសាលាខេត្តម្នាក់ ។

## ស្រុកត្បូងឃ្មុំ

### ចំការស្វាយ

មន្ទីរឃុំឃាំង និងរណ្តៅសាកសព គឺមានទីតាំងនៅប៉ែកខាងជើងនៃឃុំសូង ហើយដែលជាមន្ទីរឃុំឃាំងដែលមានរណ្តៅសំរាប់សួរចំលើយ នៅទីនោះផង ។ មន្ទីរឃុំឃាំងត្រូវបានសង់ឡើងពីឈើ និងស្លឹកត្នោត ហើយមានអណ្តូងជ្រៅ៧ពីរកន្លែង និងរណ្តៅសាកសព ១៥រណ្តៅ ដែលត្រូវបានប្រើធ្វើជាកន្លែងសម្លាប់ និងកប់សាកសពនៅជិតមន្ទីរឃុំឃាំងនោះ ។ ជនរងគ្រោះទាំងអស់គឺជាទាហានរបស់ **លន់ ណុល** និងប្រជាជនថ្មី មន្ទីរឃុំឃាំងនេះចាប់ដំណើរការពីឆ្នាំ១៩៧៦-៧៧ ហើយនៅឆ្នាំ១៩៧៨ យោធារបស់ **សោ ភឹម** ក៏ត្រូវបានសម្លាប់នៅទីនេះដែរ បន្ទាប់ពីការស្លាប់របស់ **សោ ភឹម** ។

សាក្សីម្នាក់ឈ្មោះ **ពីង សឿន** ដែលជាអ្នកបានឃើញការសម្លាប់នៅទីនេះ បានរាយការណ៍ថាជនរងគ្រោះទាំងឡាយនោះត្រូវបានពួកវានាំមកដោយរទេះគោ មកកាន់មន្ទីរឃុំឃាំងនេះ

ហើយបន្ទាប់ មកត្រូវពួកវាដោះសំលៀកបំពាក់ចេញ ។ ជនរងគ្រោះទាំងអស់ត្រូវបានចងមុខ ហើយសម្លាប់ដោយវាយ កញ្ចឹងកនឹងពូថៅ ឬ ចាក់នឹងចំពុះទុង ។

**វត្តវិហារធន្ទឹម ស្រុកត្បូងឃ្មុំ ០៣១៦០៣**

វិមានសព ដែលនៅក្នុងវត្តនេះ មានតម្កល់អដ្ឋិធាតុ ដែលត្រូវបានគាស់ពីរណ្តៅសាកសពនៅទីតាំងចំការស្វាយ និងទីតាំងចំការម្នាស់ ។ នៅទីនេះយើងបានសំភាសន៍សាក្សីម្នាក់ដែលធ្លាប់បានឃើញសាកសពរបស់ **សោ គឹម** គាត់ឈ្មោះ **ទាវ ផា** ក្រោយពេលដែលសាកសពនោះត្រូវបានគេនាំមកកាន់ឃុំសួង ដោយរថក្រោះនៅក្នុងឆ្នាំ១៩៧៨ ។ គាត់បានរាយការណ៍ថា សាកសពត្រូវបានគេដាក់តាំងនៅ ក្នុងហិបឈើចំហរមួយ នៅក្នុងផ្សារ ដែលមានដាក់ទឹកកកផង ហើយបន្ទាប់មក សាកសពនេះ ត្រូវបាននាំ យកទៅភ្នំពេញ ។ គាត់មានប្រសាសន៍បន្តទៀតថា ប្រជាជនមានទឹកមុខស្រពោន បន្ទាប់ពីបានឃើញ សាកសព ហើយមានការភ័យខ្លាចទៀតផង ។

យើងត្រូវបង្ហាញអោយឃើញផ្ទះ ដែល **សោ គឹម** ធ្លាប់ស្នាក់នៅ និងមន្ទីរស្រុករបស់គាត់នៅក្នុងឃុំសួង ។

**សាលារៀនសួង ស្រុកត្បូងឃ្មុំ ០៣១៦០៤**

វិទ្យាល័យសួង ត្រូវបានខ្មែរក្រហមប្រើធ្វើជាមន្ទីរឃុំឃាំង ពីឆ្នាំ១៩៧៥-១៩៧៧ ។ យើងបានសំភាសន៍សាក្សីម្នាក់ឈ្មោះ **ឡយ សុខ** ដែលធ្លាប់ជាអ្នកទោសនៅទីនេះ ហើយបន្ទាប់មកត្រូវបានដោះលែង ។ សរុបលើការចាប់អារម្មណ៍ដែលបានសំរេចពីការធ្វើសំភាសន៍នៅសួង ហាក់ដូចជាការបញ្ជាក់នូវចំណាប់អារម្មណ៍ថា **សោ គឹម** បានការពារប្រជាជននៅក្នុងតំបន់នេះ ពីការដែលមិនប្រែប្រួល ហើយនិងភាពគ្មានមេត្តា ដែលធ្លាប់មាននៅទីដទៃទៀត ហើយចំពោះចំនួននៃការសម្លាប់ វាហាក់ដូចជាមានចំនួនតិចជាង នៅទីនោះមកទល់នឹងការស្លាប់របស់គាត់ ។

**ចំការម្នាស់ ស្រុកត្បូងឃ្មុំ ០៣១៦០៥**

ទីតាំងរណ្តៅសាកសពនេះមានអណ្តូងពីរ ដែលនៅជាយនៃបរិវេណចំការកៅស៊ូ ដែលមានចម្ងាយ ៥គីឡូម៉ែត្រ ប៉ែកខាងជើងនៃសាលាស្រុក(សួង) សាក្សីម្នាក់បានរាយការណ៍ថា គាត់បានឃើញជនជាតិភាគតិច ដែលអតីតជាទាហានរបស់ **លន់ ណុល** រាប់រយនាក់ ត្រូវបាននាំមកកាន់ទីតាំងនេះ ដោយរទេះសេះ ក្នុងឆ្នាំ១៩៧៦ ហើយជាកន្លែងដែលពួកគេត្រូវបានសម្លាប់ នឹងបោះសាកសពរបស់ពួកគេចូលក្នុងអណ្តូងដីសែនជ្រៅ ដែលសព្វថ្ងៃអណ្តូងទាំងនោះ នៅមានរូបភាពនៅឡើយ ។

កាផា (ល្អីដែលពួកជនជាតិភាគតិចតែងតែប្រើស្ពាយពីក្រោយខ្នង សំរាប់ដាក់ឥវ៉ាន់) និងកាំបិត ព្រមទាំងឧបករណ៍ផ្សេងៗ ត្រូវបានទុកក្នុងផ្ទះមួយជិតនេះ ដែលជាកន្លែងដែលពួកគេបានឃើញ បន្ទាប់ពីថ្ងៃរំដោះ ។

**ក្បាលជ្រោយ ស្រុកត្បូងឃ្មុំ ០៣១៦០៥**

ទីតាំងសម្លាប់មនុស្ស និងរណ្តៅសាកសពដ៏ធំនេះ គឺស្ថិតនៅជិតស្ពាន ដែលតភ្ជាប់ពីផ្លូវលំ ទៅផ្លូវជាតិលេខ៧ ដែលមានចម្ងាយ ១០គីឡូម៉ែត្រ ពីកំពង់ចម្លងសាឡាង ទន្លេបិទ ដែលឆ្ពោះទៅកាន់សួង ហើយក៏ជាភាគខាងកើតនៃស្រុករបស់ខេត្តកំពង់ចាម ។

ទីតាំងនេះ គឺស្ថិតនៅក្នុងទីវាលដែលមានដីក្រហែងក្រហួង ចំពីខាងក្រោយ " រោងចក្រជប៉ុន " ដែលខ្មែរក្រហមយកមកប្រើប្រាស់ធ្វើជាឃ្លាំងសំភារៈ តែបច្ចុប្បន្នរោងចក្រនោះត្រូវបានបាក់បែកជិតអស់ហើយ ។ ទីតាំងនេះជាទីតាំងសំខាន់មួយដែរ ពីព្រោះទំហំនៃរណ្តៅ និងប្រភេទនៃជនរងគ្រោះ ដែលត្រូវបានសម្លាប់នៅទីនេះ យោងតាមសេចក្តីរាយការណ៍របស់សាក្សីទុកជាសក្ខីភាពដូចខាងក្រោម ។ ទីតាំងនេះត្រូវបានចាប់អនុវត្តពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៨ ហើយជនរងគ្រោះ ដំបូងគឺជាទាហាន **លន់ ណុល** បន្ទាប់មកប្រជាជនថ្មី (១៧ មេសា) ដែលត្រូវបាននាំមកពីស្រុកត្បូងឃ្មុំ ហើយចុងបញ្ចប់នៃការសម្លាប់ នៅឆ្នាំ១៩៧៨ គឺជាក្រុមគ្រួសារនៃទាហានរបស់ **សោ ភឹម** ។ នៅឆ្នាំ១៩៧៨នេះ ត្រាក់ទ័រចូកដី ត្រូវបានទុកជាប្រចាំនៅក្នុងទីតាំងនេះ ដើម្បីប្រើសំរាប់ជីករណ្តៅសាកសព ហើយនឹងលប់វិញ នៅពេល ដែលសម្លាប់រួច ។ រណ្តៅសាកសពមួយចំនួនត្រូវបានគាស់រួចនៅឆ្នាំ១៩៨២ ដែលមានទំហំ ១០ម៉ែត្រ គុណនឹង ៤ម៉ែត្រ ជំរៅ ២ម៉ែត្រ រណ្តៅធំៗ ត្រូវបានកប់សាកសព ជាង ១០០នាក់ ក្នុង១រណ្តៅៗ ។

សាក្សីឈ្មោះ **មិន ខួន** ជាប្រជាជនមូលដ្ឋាន បច្ចុប្បន្នជាប្រធានឃុំជីរ៉ូ២ ។ គាត់បានឃើញដោយផ្ទាល់ភ្នែកនូវការសម្លាប់ ពេលដែលគាត់បានមកឃ្វាលគោនៅទីនោះ ។ នៅឆ្នាំ១៩៧៨ គាត់បានឃើញរថយន្ត ២គ្រឿង ម៉ាក ៥០០ បានមកកាន់ទីតាំងនេះ ដោយមានផ្ទុកជនរងគ្រោះពី ៤០-៥០នាក់ ក្នុងរថយន្តនីមួយៗ ភាគច្រើនគឺជាស្ត្រី និងកូនក្មេង ។ ជនរងគ្រោះទាំងអស់ត្រូវបានសម្លាប់ដោយវាយកញ្ចឹងក និងចាក់ដោយចំពុះទុងចំពោះ ។ គាត់បានបញ្ជាក់ថា ខ្មែរក្រហមប្រើចំពុះទុងដើម្បីសម្លាប់ បើសិន ជាជនរងគ្រោះនោះបានព្យាយាមតដៃវិញ ។ ចំណែកកូនក្មេងតូចត្រូវបានសម្លាប់ដោយបោះឡើងលើ ហើយវាយនឹងដំបងទម្លាក់ក្នុងរណ្តៅ ឬ ក៏ត្រងនឹងចុងចំពុះទុង ។

គាត់បានរាយការណ៍បន្តទៀតថា ខ្មែរក្រហមបានស្រាវជ្រាវរកក្រុមគ្រួសារ សាច់ញាតិ របស់មន្ត្រី **ម៉ុល ពន** ទាំងអស់ ដែលបានក្បត់នឹងអង្គការ (យោធារបស់ **សោ ភឹម**) ហើយបានយកទៅសម្លាប់ ទាំងគ្រួសារ។ ។

សាក្សី **សៀម សឿន** (ស្រី) បានរស់នៅក្នុងឃុំនោះដែរ បានរាយការណ៍ថា ក្រុមគ្រួសាររបស់គាត់ ៦នាក់ ត្រូវបានខ្មែរក្រហមនាំយកមកសម្លាប់នៅក្នុងទីតាំងនេះដែរ ។ ដំបូងខ្មែរក្រហមមកហៅគ្រួសាររបស់គាត់ទៅកាន់វត្ត ។ នៅពេលល្ងាចមួយនោះ ពួកជនរងគ្រោះទាំងអស់ ដែលជាអតីតយោធាពិការរបស់ **ម៉ុល ពន** ត្រូវបានដឹកតាមរថយន្ត ដោយមានយោធាខ្មែរក្រហមការពារ ទៅកាន់ទីតាំងនោះ ហើយពួកគេទាំងអស់ពុំដែលឃើញបានត្រឡប់មកវិញទេ ។

## ថ្ងៃព្រហស្បតិ៍ ទី២២ ខែកុម្ភៈ ឆ្នាំ១៩៩៦

នៅព្រឹកថ្ងៃព្រហស្បតិ៍ យើងបានធ្វើដំណើរឆ្ពោះទៅកាន់ស្រុកជើងព្រៃ នៅទិសខាងលិចតាមបណ្តោយផ្លូវជាតិលេខ៧ ដែលបានជូនដំណើរដោយលោក **និន ស៊ីណាត** មកពីការិយាល័យធម្មការ និង សាសនា ។ នៅទីនោះយើងបានជួបប្រធានស្រុក និងបុគ្គលិកខ្លះរបស់គាត់ ។ ក្រោយពេលដែលបានជ្រើសរើសទីតាំងដើម្បីចុះពិនិត្យរួចមក យើងក៏បានធ្វើដំណើរចេញទៅ ដោយមានលោក **ចេក គួន** មកពីការិយាល័យធម្មការ និងសាសនា ស្រុក និងលោក **អួច អិម** មកពីការិយាល័យវប្បធម៌ និង សិល្បៈ រួមដំណើរផង ។

**វត្តស្គន់ ស្រុកជើងព្រៃ ០៣០៣០១/២**

ចេតិយ៍មួយថ្មីយ៉ាងស្អាត ដែលបានសង់ឡើងនៅក្នុងវត្តនេះ ដើម្បីធ្វើជាវិមានរំលឹក ចំពោះជនរងគ្រោះ ដែលត្រូវបានសម្លាប់នៅទីវាលពិឃាត ដែលនៅជិតនេះ ដែលត្រូវបានចំណាយលើការសាងសង់ដោយក្រុមសាច់ញាតិរបស់សាកសព ។ មានតែឆ្អឹងខ្មៅប៉ុណ្ណោះ ដែលត្រូវបានរៀបដាក់ជាជុង ជាធ្នឹម មានបែបបទជាបួនជ្រុង ទំហំ ២ម៉ែត្រ បួនជ្រុង ដែលអាចបញ្ជាក់បានថា មានចំនួនជាច្រើនពាន់ជនរងគ្រោះ ។

ចម្ងាយប្រហែល ៥០០ម៉ែត្រ ខាងលិចវត្ត គឺជាវាលសម្លាប់មនុស្សដ៏ធំមួយ ដែលមានរណ្តៅសាកសពជាច្រើន តែឥឡូវប្រែក្លាយទៅជាចំការដំណាំហូបផ្លែ គឺត្រូវបានដាំដើមស្វាយចន្ទី ។ រណ្តៅសាកសពទាំងឡាយនោះ មានទំហំ ២ម៉ែត្រការ៉េ ហើយយើងបានរាប់ឃើញថា មានចំនួនជាង៤០០រណ្តៅ ។ រណ្តៅជាច្រើនត្រូវគាស់រួចហើយ ហើយរណ្តៅនីមួយ។មានចំណុះពី ១៥ ទៅ ២០ជនរងគ្រោះ ។ បើគិតជារួម

ឃើញថា មានចំនួនជាង ៥.០០០ ជនរងគ្រោះ ដែលត្រូវបានសំលាប់នៅទីតាំងនេះ ឆ្អឹងនៃបំណែកក្រណាត់ ខោ អាវ របស់សាកសព នៅមានសេសសល់ខ្លះជុំវិញរណ្តៅសាកសព ។

សាក្សី **ខិត ខឿន** ជាប្រជាជនមូលដ្ឋាន ដែលរស់នៅក្នុងភូមិនោះដែរ គាត់បានឃើញដោយផ្ទាល់ភ្នែកនូវការសម្លាប់របស់ខ្មែរក្រហមទៅលើជនរងគ្រោះចំនួន ៣ ឬ ៤ដង នៅឆ្នាំ១៩៧៧ នៅពេលដែលគាត់ត្រូវបានពួកវាប្រើឱ្យមកកាប់ឫស្សីធ្វើបង្គោងឡើងត្នោត គាត់បានរាយការណ៍ថា ជនរងគ្រោះភាគច្រើនជាប្រជាជនថ្មី មានបុរស ស្ត្រី និងកូនក្មេង ពួកគេត្រូវបាននាំយកមកកាន់ផ្ទះសន្តិសុខតាមរថយន្ត បន្ទាប់មក ជនរងគ្រោះទាំងអស់ត្រូវបានខ្មែរក្រហមដោះសំលៀកបំពាក់ចេញ ទុកតែខោខ្លី រួចបណ្តើរយកទៅកាន់រណ្តៅសាកសព ។ សំលៀកបំពាក់របស់ជនរងគ្រោះគរដូចជំបូក នៅក្បែរផ្ទះនោះ ។ ជនរងគ្រោះត្រូវបានសម្លាប់ដោយវាយក្បាលពីក្រោយ ដោយដែកភ្ជួររទេះ ដែកភ្ជួររទេះនោះឡើង ងរ បន្ទាប់ពីសម្លាប់រួច ។ ចំណែកកូនក្មេងត្រូវបានចាប់ជើងគ្រវី រួចបោកក្បាលនឹងដើមឈើ ។

ជនរងគ្រោះត្រូវបានចាក់ពោះដោយចំពុះទុង មុនពេលទំលាក់ចូលក្នុងរណ្តៅ ។ យោងតាមសំដីរបស់សាក្សីបានអោយដឹងថា ការចាក់ពោះនេះ គឺដើម្បីការពារកុំអោយសាកសពហើមប៉ោមខ្លាំងពេក ហើយអាចដាក់សាកសពបានច្រើនក្នុងរណ្តៅនីមួយៗ ។

## ជីតាផ្រាំង ស្រុកជើងព្រៃ ០៣០៣០៣

ទីតាំងរណ្តៅសាកសពនេះ នៅជិតផ្លូវជាតិលេខ៧ ប្រហែល ៥០គីឡូម៉ែត្រ ខាងលិចទីរួមខេត្តកំពង់ចាម ហើយបានស្ថិតនៅក្នុងដី ដែលគេបោះបង់ចោលពីក្រោយសាលារៀន ក្នុងភូមិបាណា ។ យើងបានរាប់ឃើញថា មានរណ្តៅសាកសពតូចៗ ចំនួនជាង ១០០រណ្តៅ ហើយព្រមទាំងមានបំណែកសំលៀកបំពាក់ និងឆ្អឹងសាកសពខ្លះ នៅរាយប៉ាយជុំវិញទីនោះ ។ ការសម្លាប់ដែលបានអនុវត្តនៅទីតាំងនេះ គឺនៅឆ្នាំ១៩៧៧ ដល់ ១៩៧៨ តាមការប៉ាន់ស្មាន ឃើញថាមានជនរងគ្រោះចំនួន ២.០០០នាក់ ត្រូវបានសំលាប់នៅទីនោះ ។

## ឡប្បុង ស្រុកជើងព្រៃ ០៣០៣០៤/០៥

មន្ទីរឃុំឃាំង និងរណ្តៅសាកសពដ៏ធំនេះ គឺស្ថិតនៅជិតផ្លូវជាតិលេខ៧ ប្រហែលជាពាក់កណ្តាលផ្លូវពីភ្នំពេញទៅកំពង់ចាម ។ មន្ទីរឃុំឃាំងនេះ គឺត្រូវបានសង់ឡើងដើម្បីធ្វើជាមន្ទីរឃុំឃាំង ហើយត្រូវសង់អំពីឈើ និងស្លឹកត្នោត នៅក្នុងឆ្នាំ១៩៧៤ គឺមុនពេលដែលទីក្រុងភ្នំពេញ ត្រូវបានកាន់កាប់ដោយពួកខ្មែរក្រហម នៅឆ្នាំ១៩៧៥ ដែលមានការទាក់ទងដោយទាហាន **លន់ ណុល** ។

មានមន្ទីរឃុំឃាំងមួយសំខាន់ជាងគេ ហើយនិងសំណង់ សន្តិសុខ ២ ឬ ៣ ខ្នងទៀត ដែលហ៊ុំព័ទ្ធដោយរបងឫស្សីខ្ពស់ៗ ។

សាក្សីឈ្មោះ **ចេក ឈួន** គឺជាជាងឈើ នៅពេលនោះ ហើយបានធ្លាប់ធ្វើឱ្យពួកខ្មែរក្រហម។

នៅពេលដែលគាត់បានមើលទៅក្នុងមន្ទីរឃុំឃាំងតាមប្រឡោះរបង គាត់ឃើញជនរងគ្រោះ ( អ្នកទោស) អង្គុយពីរជួរទល់មុខគ្នា បុរសមួយជួរ ស្ត្រីមួយជួរ ហើយពួកគេត្រូវបានដាក់ខ្នោះ យ៉ាងតឹងដោយរបារដែក វែង ស៊កខ្ទាស់ ចាក់សោរនៅខាងចុងរបារដែក ។

ប្រហែលជា ៥០០ម៉ែត្រ ខាងត្បូងមន្ទីរឃុំឃាំង មានទីតាំងកប់សាកសព ២កន្លែង ដែលគិតសរុបទៅប្រហែលជាជាង ៤០០រណ្តៅ សាកសព ។ រណ្តៅសាកសពទាំងនេះ មិនដែលត្រូវបានគាស់ទេ លើកលែងតែពួកចោរគាស់រកមាស ហើយមានបំណែកឆ្អឹង និងកំទេចក្រណាត់ ខោ អាវ របស់ជនរងគ្រោះនៅរាយប៉ាយក្បែរមាត់រណ្តៅទាំងនេះ ។

**<u>សេចក្តីសន្និដ្ឋាន</u>**

ការចុះពិនិត្យរបស់យើងនៅខេត្តកំពង់ចាម នៅឆ្នាំ១៩៩៥ គឺមានសារៈសំខាន់ណាស់ពីព្រោះមាន ចំណុច ២យ៉ាង : ទី១ គឺជាភស្តុតាងផ្ទាល់ ដែលយើងបានឃើញនូវទីកន្លែងដែលជាទីប្រជុំជនរបស់ប្រជា ជនចាម ដែលត្រូវបានពួកខ្មែរក្រហមសម្លាប់នៅក្នុងស្រុកក្រូចឆ្មារ ហើយភស្តុតាងចំពោះមុខ គឺទីតាំង ពិឃាត និងមន្ទីរឃុំឃាំងនៅវត្តភ្នំប្រុស និងវត្តស្ទឹងត្រង់ ។

ការចុះពិនិត្យទីតាំងនៅឆ្នាំ១៩៩៦ ទាំងអស់ សុទ្ធតែជាទំហំមួយថ្មី លើទីតាំងប្រល័យពូជសាសន៍ដែលលាតសន្ធឹងតាមដងទន្លេ ក្នុងខេត្តកំពង់ចាម ។

គំរូនៃការសម្លាប់ដ៏ធំនេះ ហើយនឹងទីតាំងកប់សាកសព ដែលមានឡើងតាមបណ្តោយទន្លេមេគង្គ និងផ្លូវជាតិលេខ៧ ដែលជាការងាយស្រួលដល់ទីប្រជុំនៃមធ្យោបាយធ្វើដំណើរ ដែលឈរនៅលើកត្តានៃការសំរេចចិត្ត ។ រឿងនោះថា ដូចជាមានទីតាំងជាច្រើនទៀត ដែលនឹងត្រូវបានរកឃើញ តាមបណ្តោយដងទន្លេមេគង្គ ក្នុងខេត្តកំពង់ចាម ព្រៃវែង កណ្តាល មុនពេលដែលយើងបញ្ចប់នូវការងាររបស់យើង ។

សរុបមកលើទីតាំងរណ្តៅកប់សាកសពមាន ១២កន្លែង ដែលយើងបានចុះត្រួតពិនិត្យរួចក្នុងរយៈ កាលនៃការចុះត្រួតពិនិត្យ នៅខេត្តកំពង់ចាម ។ យើងបានរកឃើញនូវចំនួនសរុបនៃរណ្តៅសាកសព មាន ចំនួន ១.៧៤០ រណ្តៅ តាមការប៉ាន់ស្មានចំនួនជនរងគ្រោះ ដែលត្រូវបានសម្លាប់នៅទីតាំងទាំងអស់នេះ មានចំនួន ៩៦.៨៥០នាក់ ។

**ឆាលីស ថឺរទ័រ**

ថ្ងៃទី ២៣ ខែតុលា ឆ្នាំ១៩៩៥

បានបញ្ចប់ដោយបន្ថែមទីតាំងមួយចំនួនទៀត

ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៩៦